# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងរវាង
## ក្រុមហ៊ុន ហែលសា សៅអ៊ិស អេស៊ា ខូ អិលធីឌី
## និង ប្រតិភូបុគ្គលិកពេញសិទ្ធិ

កាលពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០២៣វេលាម៉ោង ប្រាំបួនព្រឹកនៅក្នុងក្រុមហ៊ុន **ហែលសា សៅអ៊ិស អេស៊ា ខូ អិលធីឌី** មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និង តំណាងប្រតិភូបុគ្គលិក ។ដែលនៅក្នុងកិច្ចប្រជុំតំណាងក្រុមហ៊ុនបានជូនដំណឹងដល់តំណាងប្រតិភូបុគ្គលិកទាំងអស់ អំពីស្ថានភាពជាក់ស្តែងដែលខាងក្រុមហ៊ុនមិនមានការបញ្ជាទិញធ្វើអោយប៉ះពាល់ដល់សង្វាក់ផលិតកម្មរបស់រោងចក្រហេតុដូច្នេះហើយក្រុមហ៊ុនសំរេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ២០នាក់ ស្រី ០៥ នាក់ ក្នុងចំណោមកម្មករនិយោជិតចំនួន ១៣៩ នាក់ ស្រី ៣៩ នាក់ រយះពេល ៣០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣ ។ ដោយក្នុងរយះពេលព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុនបានព្រមព្រៀងក្នុងការផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០ ដុល្លារអាមេរិច កំឡុងពេលព្យួរ សម្រាប់កម្មករនិយោជិតម្នាក់ៗ ដែលទូទាត់ជូននៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២៣ ( មកបើកដោយផ្ទាល់នៅក្នុងក្រុមហ៊ុន **ហែលសា សៅអ៊ិស អេស៊ា ខូអិលធីឌី** ) ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ១០ព្រឹកនាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និទស្នាលនិងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន ។

ថ្ងៃ សុក្រ ៧កើត ខែ ជេស្ឋ ឆ្នាំ ថោះ បញ្ចស័ក ២៥៦៧
ស្វាយរៀងថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០២៣
ជ.នាយកក្រុមហ៊ុន

Helsa South East Asia Co., Ltd.

វ៉ន ស្រីនាង

**ហត្ថលេខា ឬស្នាមមេដៃប្រតិភូបុគ្គលិកពេញសិទ្ធិ**

លោកស្រី ចន សុគន្ធា ..................................

លោក ឈួន រ៉ាទិត្រ ..................................